ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ ១៣៨
ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខ ៣០៨
ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២
**សាលក្រមព្រហ្មទណ្ឌ**
**លេខ: ៤៤ "ឈ"/៤៥៩**
ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តសៀមរាប ។
នាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ វេលា រសៀល ។

**ដែលមានសមាសភាព**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ឋានៈ ចៅក្រម

**តំណាងអយ្យការ**

លោកស្រី [redacted] ឋានៈ ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ឋានៈ ក្រឡាបញ្ជី

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១៣៨ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] ណាម៉ាប់ ភេទស្រី កើតឆ្នាំ១៩៩៨ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលចាប់ខ្លួននៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ មិនចេះអក្សរ មុខរបររើសអេតចាយ ឪពុកឈ្មោះ [redacted] ណា "ស្លាប់" ម្តាយមិនស្គាល់ "ស្លាប់" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មាន ។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៤ ឃ.ខ/៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ ។

២.ឈ្មោះ [redacted] ប៊ុន្នី ភេទស្រី កើតឆ្នាំ១៩៦២ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលចាប់ខ្លួននៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌មិនចេះអក្សរ មុខរបរនៅផ្ទះ ឪពុកឈ្មោះ [redacted] សឿន "ស្លាប់" ម្តាយឈ្មោះ [redacted] ផៃ "ស្លាប់" មេម៉ាយមានកូន០៤នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មាន ។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៥ ឃ.ខ/៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

## អង្គហេតុកើតឡើងមានដូចតទៅ៖

កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១០.០០នាទីយប់ កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថក្រុងសៀមរាប បានទទួលការរាយការណ៍ពីប្រជាពលរដ្ឋថា មានជនសង្ស័យកំពុងចែកចាយថ្នាំញៀននៅចំណុចភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។ បន្ទាប់មកសមត្ថកិច្ចបានចុះទៅបង្ក្រាប និងឃាត់បានឈ្មោះ [redacted] ប៊ុន្នី និងឈ្មោះ [redacted] ណាម៉ាប់ ព្រមទាំងបានឆែកឆេររកឃើញថ្នាំញៀនចំនួន ១ (មួយ) កញ្ចប់ ទម្ងន់ ០,២១ (សូន្យក្បៀសម្ភៃមួយ)ក្រាម និងប្រាក់ចំនួន ៣០.០០០ (បីម៉ឺន)រៀល ដែលបានមកពីការលក់ថ្នាំញៀន ។

បានឃើញ របាយការណ៍សរុបលេខ ០១៩/២២ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថខេត្តសៀមរាប ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២០៨ អយធ/២២ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៧៣៧ ពស.ព្រស/ញ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៣២៩ ពស.ព្រជ/ក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ឯកសារនានាក្នុងសំណុំរឿងលេខ ១៣៨ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ ។

## នាពេលសវនាការ

-ក្រោយពីបាន ស្តាប់ចម្លើយ និងអំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបាន ស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបាន ពិនិត្យលើភស្តុតាងឯកសារផ្សេងៗក្នុងសំណុំរឿង

-ក្រោយពីបាន ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តសៀមរាប

## យល់ឃើញថា៖

១.តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៧៣៧ ពស.ព្រស/ញ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ណាម៉ាប់ និងឈ្មោះ [redacted] ប៊ុន្នី មកជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២.ជនជាប់ចោទឈ្មោះ [redacted] ណាម៉ាប់ បានឆ្លើយបដិសេធនាពេលសវនាការថា ខ្លួនគ្រូវជាកូនចញ្ចឹមរបស់ឈ្មោះ [redacted] ប៊ុន្នី ដែលគាត់បានមើលថែខ្លួនតាំងពីទារកមកម្លេះ ។ ឈ្មោះ [redacted] ប៊ុន្នី ពុំដែលវាយធ្វើបាបខ្លួនទេ ហើយខ្លួនក៏ពុំធ្លាប់មានជម្លោះជាមួយគាត់ដែរ ។ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ៧ព្រឹក មានមនុស្សប្រុសម្នាក់សួររកទិញថ្នាំញៀនពីខ្លួនតែខ្លួនពុំមានទេ លុះដល់ម៉ោងប្រហែល ១០ព្រឹក ថ្ងៃខែឆ្នាំដដែល ក៏មានមនុស្សប្រុសម្នាក់ផ្សេងទៀតមកសួររកទិញថ្នាំញៀនពីខ្លួនតែខ្លួនពុំមានទេ ។ មួយសន្ទុះក្រោយមកក៏មានសមត្ថកិច្ចមកដល់ ហើយធ្វើការដកហូតថ្នាំញៀននៅគុម្ពចេកចំនួន ១ (មួយ)

កញ្ចប់ និងដកហូតប្រាក់ពីខ្លួនចំនួន ៣០.០០០ (បីម៉ឺន)រៀល ។ ថ្នាំញៀននេះពុំមែនជារបស់ខ្លួនទេ មិនដឹងរបស់អ្នកណាទេ ប្រាក់ដែលសមត្ថកិច្ចដកហូតនេះ គឺមនុស្សប្រុសពុំស្គាល់នោះហុចឲ្យខ្លួនមិនដឹងថាជាថ្លៃអ្វីទេ ។ ខ្លួនមិនចេះប្រើប្រាស់ថ្នាំញៀនទេ ហើយខ្លួនក៏ពុំស្គាល់ថ្នាំញៀនដែរ ម្តាយចិញ្ចឹមរបស់ខ្លួនពុំធ្លាប់លក់ថ្នាំញៀនទេ ។ ចម្លើយបដិសេធនាពេលសវនាការរបស់ជនជាប់ចោទរូបនេះពុំមានភស្តុតាងណាមកបញ្ជាក់អាចឲ្យតុលាការជឿបានឡើយ បើផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទរូបនេះផ្ទាល់នៅដំណាក់កាលចៅក្រមស៊ើបសួរ និងនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយសារភាពប្រហាក់ប្រហែលគ្នាថា កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១១ព្រឹក មានមនុស្សប្រុសពីរនាក់មកសួររកទិញថ្នាំញៀនពីអ៊ុំខ្លួន ពេលនោះខ្លួនបានទៅប្រាប់អ៊ុំឈ្មោះ [redacted] ប៊ុន្នី ហើយអ៊ុំខ្លួនស្រែកសួរពីផ្ទះបាយមកថា អ្នកណាគេ? មនុស្សប្រុសទាំងពីរនាក់នោះឆ្លើយថា បាទអ៊ុំខ្ញុំ! ដោយអ៊ុំខ្លួនស្គាល់បុរសទាំងពីរនាក់នោះក៏បានឲ្យថ្នាំញៀនចំនួន ១ (មួយ)កញ្ចប់ មកឲ្យខ្លួន ហើយខ្លួនក៏យកថ្នាំញៀននោះទៅឲ្យបុរសទាំងពីរនាក់នោះគេក៏ប្រគល់ប្រាក់ឲ្យមកខ្លួនមិនដឹងចំនួនប៉ុន្មានទេ ខ្លួនក៏យកប្រាក់នោះឲ្យទៅអ៊ុំនៅផ្ទះបាយមួយសន្ទុះក្រោយមកក៏មានសមត្ថកិច្ចមកឃាត់ខ្លួន និងដកហូតប្រាក់ចំនួន ៣០.០០០ (បីម៉ឺន)រៀល ពីអ៊ុំរបស់ខ្លួន និងថ្នាំញៀនចំនួន ១ (មួយ)កញ្ចប់ ថែមទៀត ។ ដូចនេះ តុលាការអាចសន្និដ្ឋានបានថាជនជាប់ចោទឈ្មោះ [redacted] ណាម៉ាប់ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។

៣.ជនជាប់ចោទឈ្មោះ [redacted] ប៊ុន្នី បានឆ្លើយបដិសេធនាពេលសវនាការថា ឈ្មោះ [redacted] ណាម៉ាប់ ខ្លួនបានយកគេមកចិញ្ចឹមតាំងពីនៅជាទារកមកម្លេះ ដោយសារឪពុកម្តាយរបស់គេស្លាប់តាំងពីគេនៅជាទារក ។ ឈ្មោះ [redacted] ណាម៉ាប់ ជាមនុស្សមានសតិពុំសូវគ្រប់ប៉ុន្មានទេ ។ ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នេះទេ ខ្លួនពុំស្គាល់អ្វីជាថ្នាំញៀនឡើយ ហើយខ្លួនក៏មិនចេះប្រើប្រាស់ថ្នាំញៀនដែរ ។ ខ្លួនមិនធ្លាប់លក់ថ្នាំញៀនទេ សមត្ថកិច្ចមកឃាត់ខ្លួនបានដកហូតប្រាក់ចំនួន ៣០.០០០ (បីម៉ឺន)រៀល មិនមែនជាប្រាក់ថ្លៃថ្នាំញៀនទេ ចំណែកថ្នាំញៀនដែលសមត្ថកិច្ចដកហូតនេះមិនមែនជារបស់ខ្លួនទេ ។ ចម្លើយបដិសេធនាពេលសវនាការរបស់ជនជាប់ចោទរូបនេះ ពុំមានភស្តុតាងណាមកបញ្ជាក់អាចឲ្យតុលាការជឿបានឡើយ បើផ្អែកតាមចម្លើយរបស់ជនជាប់ចោទរូបនេះផ្ទាល់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌បានឆ្លើយសារភាពថា កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១០ព្រឹក មានមនុស្សប្រុសម្នាក់ជិះម៉ូតូម៉ាក ហុងដាសេ១២៥ ពណ៌ក្រហម ស៊េរីឆ្នាំ២០២១ បានយកថ្នាំញៀនមកឲ្យខ្លួន ហើយប្រាប់ថា ទុកលក់ឲ្យគេទៅគេនឹងឲ្យប្រាក់ឈ្នួល ៥.០០០ (ប្រាំពាន់)រៀល ។ លុះដល់ម៉ោងប្រហែល ១១ ថ្ងៃខែឆ្នាំដដែល មានមនុស្សប្រុសពីរនាក់មកដល់ខ្លួនក៏បានឲ្យថ្នាំញៀននោះទៅឈ្មោះ [redacted] ណាម៉ាប់ ដើម្បីយកទៅលក់ឲ្យគេតម្លៃ ៣០.០០០ (បីម៉ឺន) រៀល ភ្លាមនោះមានសមត្ថកិច្ចមកដល់ឃាត់ខ្លួនដកហូតថ្នាំញៀនចំនួន ១ (មួយ)កញ្ចប់ និងប្រាក់ចំនួន ៣០.០០០ (បីម៉ឺន)រៀល នេះតែម្តង ។ មួយទៀតផ្អែកតាមចម្លើយរបស់ឈ្មោះ [redacted] ណាម៉ាប់ ក្នុងសំអាងហេតុចំណុចទី២ ខាងលើ និងការឃាត់ខ្លួនជាក់ស្តែងលើជនជាប់ចោទឈ្មោះ [redacted] ប៊ុន្នី ដកហូតថ្នាំញៀនចំនួន ១ (មួយ)កញ្ចប់ និងប្រាក់ចំនួន ៣០.០០០ (បីម៉ឺន)រៀល ។ ដូចនេះ តុលាការអាចសន្និដ្ឋានបានថាជនជាប់ចោទឈ្មោះ [redacted] ប៊ុន្នី ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។

៤.តាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថខេត្តសៀមរាប បានធ្វើការដកហូតថ្នាំញៀនចំនួន ១ (មួយ)កញ្ចប់ ទម្ងន់ ០,២១ (សូន្យក្បៀសម្ភៃមួយ) ក្រាម និងប្រាក់ចំនួន ៣០.០០០ (បីម៉ឺន) រៀល ពីឈ្មោះ [redacted] ប៊ុន្នី និងឈ្មោះ [redacted] ណាម៉ាប់ ហើយជនជាប់ចោទឈ្មោះ [redacted] ប៊ុន្នី និងឈ្មោះ [redacted] ណាម៉ាប់ ក៏ទទួលស្គាល់

វត្ថុចាប់យកទាំងនេះថា ជារបស់ខ្លួនមានដូចក្នុងកំណត់ហេតុទទួលស្គាល់វត្ថុតាងចាប់យក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ ដែលភស្តុតាងទាំងនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុន្នី និងឈ្មោះ [redacted] ណាម៉ាប់ ខាងលើ ដែលអាចឲ្យតុលាការសន្និដ្ឋានបានថា ជនជាប់ចោទទាំងពីរនាក់ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។

៥.តាមកំណត់ហេតុស្តីពីការបើក ដកយក ថ្លឹង បិទកញ្ចប់វត្ថុតាងដែលសង្ស័យថាជាគ្រឿងញៀនដើម្បីធ្វើកោសលវិច័យ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប បានបញ្ជាក់ថា ថ្នាំញៀនចំនួន ១ (មួយ)កញ្ចប់ របស់ឈ្មោះ [redacted] ប៊ុន្នី និងឈ្មោះ [redacted] ណាម៉ាប់ មានទម្ងន់ ០.២២ (សូន្យក្បៀសម្ភៃពីរ)ក្រាម (ថ្លឹងទាំងសំបកថង់) បានបញ្ជូនទៅធ្វើកោសលវិច័យទាំងអស់។

៦.ជនជាប់ចោទឈ្មោះ [redacted] ប៊ុន្នី និងឈ្មោះ [redacted] ណាម៉ាប់ ជានីតិជន ប្រព្រឹត្តអំពើក្នុងចេតនាទុច្ចរិត ជាមនុស្សមានស្មារតីល្អ និងមានការយល់ដឹងច្បាស់លាស់ពីអំពើ និងបច្ច័យដែលកើតមានឡើងនៃអំពើរបស់ខ្លួន តែជនជាប់ចោទឈ្មោះ [redacted] ប៊ុន្នី និងឈ្មោះ [redacted] ណាម៉ាប់ នៅតែប្រព្រឹត្តបទល្មើសដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសាធារណៈ សន្តិសុខសង្គម និងសុខភាពមនុស្សគួរឲ្យព្រួយបារម្ភ ពិសេសខុសនឹងច្បាប់រដ្ឋជាធរមាន។

៧.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុន្នី និងឈ្មោះ [redacted] ណាម៉ាប់ ដែលមានចេតនាទុច្ចរិតទិញថ្នាំញៀនសម្រាប់លក់ ដើម្បីយកប្រាក់ចំណេញ ឬដោះដូរដោយសុខច្បាប់នូវសារធាតុញៀន ដែលអំពើនេះកំណត់បានជាបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៣ និងកថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៨.មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ប៊ុន្នី និងឈ្មោះ [redacted] ណាម៉ាប់ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៩.វត្ថុចាប់យកមាន ម្សៅក្រាមពណ៌សថ្លាចំនួន ១ (មួយ)កញ្ចប់ មានទម្ងន់ 0.២២ (សូន្យក្បៀសម្ភៃពីរ)ក្រាម ដែលបានបញ្ជូនទៅធ្វើកោសលវិច័យទាំងអស់ តាមកំណត់ហេតុស្តីពីការបើក ដកយក ថ្លឹង បិទកញ្ចប់វត្ថុតាងដែលសង្ស័យថាជាគ្រឿងញៀនដើម្បី ធ្វើកោសលវិច័យ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប ឃើញថា ជាគ្រឿងញៀនដែលពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសគ្រឿងញៀន ដូចនេះតុលាការគប្បីសម្រេចរឹបអូស តាមមាត្រា ៦២ មាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ មាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១០.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានបញ្ចប់ការសួរដេញដោល ពិនិត្យភស្តុតាង និងតាមចម្លើយរបស់ជនជាប់ចោទ ឃើញថា នាពេលសវនាការជនជាប់ចោទទាំងពីរនាក់បានឆ្លើយបដិសេធថា ពុំបានលក់ថ្នាំញៀន ហើយមិនស្គាល់ថ្នាំញៀននោះទេ នេះគ្រាន់តែជាចម្លើយដោះសាររបស់ជនជាប់ចោទតែប៉ុណ្ណោះ ពុំមានភស្តុតាងណាបញ្ជាក់អាចឲ្យតំណាងអយ្យការជឿបានឡើយ។ ចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងចៅក្រមស៊ើបសួរមានភាពស៊ីសង្វាក់គ្នាជាមួយភស្តុតាងដែលជាថ្នាំញៀន និងប្រាក់ដែលសមត្ថកិច្ចដកហូតបានក្នុងបទល្មើសជាក់

ស្តែង ។ ដូចនេះ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ដូចនៅក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទាំងពីរនាក់តាមច្បាប់ ។

១១.លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុន្នី បានធ្វើសេចក្តីសន្និដ្ឋាន ថា ជនជាប់ចោទបានឆ្លើយបដិសេធទាំងស្រុងថា គាត់មិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តុលាការ ដូច្នេះស្នើសុំតុលាការឲ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ខាងលើដោយក្តីអនុគ្រោះ ។

១២.សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ណាម៉ាប់ និងឈ្មោះ [redacted] ប៊ុន្នី បានសំណូមពរមកតុលាការថា សូមឱ្យតុលាការជួយដោះលែងខ្លួនឲ្យមានសេរីភាពវិញ ។

## ហេតុដូច្នេះ សាលាដំបូងខេត្តសៀមរាប
## វិនិច្ឆ័យសេចក្តី

**១.ផ្តន្ទាទោស៖**

ក.ឈ្មោះ [redacted] ណាម៉ាប់ ភេទស្រី កើតឆ្នាំ១៩៩៨ ជនជាតិខ្មែរ (ដែលមានអត្តសញ្ញាណដូចខាងលើ) ។

ខ.ឈ្មោះ [redacted] ប៊ុន្នី ភេទស្រី កើតឆ្នាំ១៩៦២ ជនជាតិខ្មែរ (ដែលមានអត្តសញ្ញាណដូចខាងលើ) ។

**ដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈពេល ២ (ពីរ)ឆ្នាំ ៦ (ប្រាំមួយ)ខែ ។**

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**២.**វត្ថុចាប់យកមាន៖ ម្សៅគ្រីមពណ៌សថ្លាចំនួន ១ (មួយ) កញ្ចប់ ទម្ងន់ ០,២២ (សូន្យក្បៀសម្ភៃពីរ)ក្រាម ត្រូវរឹបអូសតាមបញ្ញត្តិមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ណាម៉ាប់ និងឈ្មោះ [redacted] ប៊ុន្នី ។

មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

[redacted]

[redacted]

បានថតចម្លងត្រឹមត្រូវចេញពីច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប ថ្ងៃទី៣ ខែ ឧសភា ឆ្នាំ២០២៣
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner